# អង្គការអាក់សិនអេតកម្ពុជា

# ផែនការយុទ្ធសាស្ត្រប្រចាំប្រទេស ឆ្នាំ២០២៣-២០២៧

# ActionAid Cambodia Country Strategy Paper 2023-2027



ឆ្ពោះទៅកាន់អនាគតកាន់តែប្រសើរសម្រាប់ទាំងអស់គ្នា | In the relentless pursuit of a better future for all

actionaid



# អំពីអាក់សិនអេត

កាតាលីករសម្រាប់ការផ្លាស់ប្តូរ

**អង្គការអាក់សិនអេតកម្ពុជា** ដើរតួជាកាតាលីករ និងជាអ្នករួមចំណែកដល់ដំណើរការផ្លាស់ប្រែសង្គម។ អង្គការអាក់សិនអេតកម្ពុជា ចង់ឃើញប្រជាជនកម្ពុជា ជាពិសេសស្ត្រី និងយុវជន ចូលរួមដោយសមធម៌នៅគ្រប់កម្រិតទាំងអស់ក្នុងដំណើរការអភិវឌ្ឍន៍ ដើម្បីសម្រេចបានយុត្តិធម៌សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលនាំទៅរកការទទួលបាននូវភាពប្រសើរឡើងនៃគុណភាពជីវិត តាមរយៈការបែងចែកនូវធនធានដោយយុត្តិធម៌ ការចិញ្ចឹមជីវិតដោយចីរភាព និងការទទួលបានសេវាសាធារណៈដោយមិនគិតថ្លៃ និងប្រកបដោយគុណភាព។

យើងធ្វើការជាមួយបុរស ស្ត្រី និងកុមារដែលរស់នៅក្នុងភាពក្រីក្រ និងមិនត្រូវបានរាប់បញ្ចូល។ យើងប្តេជ្ញាចិត្តរយៈពេលវែងមួយ ដើម្បីលើកកម្ពស់សិទ្ធិ ក៏ដូចជាការផ្លាស់ប្តូរពិភពលោកមួយដែលមានភាពប្រសើរឡើងសម្រាប់អនាគតកូនៗរបស់ពួកគេ។

## កម្មវិធីជាអាទិភាព

០១



ការបន្សាំទៅនឹង
ការប្រែប្រួលអាកាសធាតុ
និងការកសាងភាពធន់

០២



គុណភាពអប់រំ
បច្ចេកវិទ្យា និងជំនាញបំណិនជីវិត
ដែលមានភាពធន់

០៣



ការប្រមូល និងបែងចែកធនធាន
សម្រាប់សេវាសាធារណៈ
ឆ្លើយតបនឹងយេនឌ័រ

# វិធីសាស្ត្រអភិវឌ្ឍន៍ផ្អែកលើសិទ្ធិមនុស្ស

អង្គការអាក់សិនអេតកម្ពុជា ប្រកាន់យកវិធីសាស្ត្រអភិវឌ្ឍន៍ផ្អែកលើសិទ្ធិ ដោយឈរលើ គោលការណ៍ដឹកនាំបែបស្ត្រីនិយម នៅគ្រប់វិស័យទាំងអស់នៃការងារយើង ដើម្បីធានាឱ្យមានការចូលរួមស្មើគ្នានៅក្នុងដំណើរការធ្វើការសម្រេចចិត្តនៅគ្រប់កម្រិតទាំងអស់។



## ភាពជាដៃគូ

អង្គការអាក់សិនអេតកម្ពុជា ធ្វើការរួមគ្នាជាមួយអង្គការសង្គមស៊ីវិល សហជីព និងបណ្តាញសហគមន៍ដើម្បីបង្កើតការផ្លាស់ប្រែប្រកបដោយអត្ថន័យ។ បេសកកម្មរបស់យើង គឺដើម្បីចូលរួមយ៉ាងជិតស្និទ្ធ ជាមួយប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ រួមទាំង**កសិករខ្នាតតូច សហគមន៍នេសាទ តំបន់ការពារ កុមារ និងយុវជន** គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងការពារសិទ្ធិក្នុងការចិញ្ចឹមជីវិត និងធនធានរបស់ពួកគេ។

យើងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការតស៊ូមតិសម្រាប់ការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ ឬរដ្ឋក្នុងការបែងចែកធនធានដោយយុត្តិធម៌ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ឆ្លើយតបនឹងយេនឌ័រ ជាពិសេសក្នុងវិស័យអប់រំ និងសុខភាព។ យើងក៏ប្តេជ្ញាពង្រឹងការដោះស្រាយបញ្ហាឫសគល់នៃអំពើហិង្សាលើស្ត្រី និងកុមារី និងជំរុញយុត្តិធម៌ផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។




## តំបន់គោលដៅ

អង្គការអាក់សិនអេតកម្ពុជាធ្វើការនៅក្នុងខេត្ត និងរាជធានីចំនួន ៦ រួមមាន**ខេត្តកំពត កោះកុង ពោធិ៍សាត់ កំពង់ធំ ឧត្តរមានជ័យ និងភ្នំពេញ**។

អង្គការអាក់សិនអេតកម្ពុជាក៏មានគម្រោងពង្រីកតំបន់គោលដៅបន្ថែមនៅតំបន់ឆ្នេរ និងតំបន់ទន្លេសាប ដើម្បីពង្រឹងបណ្តាញនេសាទ តំបន់ការពារធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាជន។



# ការបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ និងការកសាងភាពធន់

## លទ្ធផលផ្លាស់ប្តូរ

ស្ត្រី និងយុវជនដឹកនាំការកសាងអោយមានភាពធន់កាន់តែប្រសើរឡើងទៅនឹងការប្រែប្រួលអាកាសធាតុ និងលទ្ធភាពប្រើប្រាស់ធនធានប្រកបដោយចីរភាពសម្រាប់គ្រួសារ និងសហគមន៍របស់ពួកគាត់។

## ផលជះជាយុទ្ធសាស្ត្រ

- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- ទំរង់មុខរបរការចិញ្ចឹមជីវិតដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការទទួលបានធនធានប្រកបដោយចីរភាព
- ការពង្រឹងគោលនយោបាយ និងគណនេយ្យភាពរបស់រដ្ឋ និងវិស័យឯកជនក្នុងការគ្រប់គ្រងធនធានធម្មជាតិ ការប្រតិបត្តិតាមគោលការណ៍កសិកូឡូស៊ី និងយុត្តិធម៌អាកាសធាតុ





# គុណភាពអប់រំ បច្ចេកវិទ្យា និងជំនាញបំណិនជីវិត ដែលមានភាពធន់

## លទ្ធផលផ្លាស់ប្តូរ

កុមារទទួលបានការអប់រំកាន់តែប្រសើរឡើង និងប្រកបដោយគុណភាពព្រមទាំងការបណ្តុះបណ្តាលបច្ចេកវិទ្យាដែលរួមបញ្ចូលការអប់រំអំពីបំណិនជីវិតដែលមានភាពធន់នៅមូលដ្ឋាន។

## ផលជះជាយុទ្ធសាស្ត្រ

- គុណភាពនៃការបង្រៀនប្រសើរឡើង តាមរយៈវិធីសាស្ត្របង្រៀនបែបច្នៃប្រឌិត
- ការលើកកម្ពស់ការអប់រំសម្រាប់កុមារ និងមនុស្សវ័យក្មេង ដែលសមស្របទៅនឹងកម្រិតសិក្សា និងកំរិតជំនាញព័ត៌មានវិទ្យាដែលត្រូវការ ក៏ដូចជាការបង្កើនជំនាញសង្គមតាមរយៈកម្មវិធីអប់រំបំណិនជីវិតដែលមានភាពធន់នៅមូលដ្ឋាន
- ការត្រួតពិនិត្យគុណភាពអប់រំនៅតាមសាលារៀនប្រសើរឡើង តាមរយៈការពង្រឹងការចូលរួមរបស់សហគមន៍ និងភាពជាម្ចាស់ និងភាពទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសាលារៀន
- ឥទ្ធិពលលើការរៀបចំគោលនយោបាយអប់រំ និងការអនុវត្ត នៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ





# ការប្រមូល និងបែងចែក ធនធានសម្រាប់សេវាសាធារណៈ ឆ្លើយតបនឹងយេនឌ័រ

## លទ្ធផលផ្លាស់ប្តូរ

ការបង្កើនការចូលរួមរបស់សាធារណៈ ក្នុងការជំរុញអភិបាលកិច្ចសេដ្ឋកិច្ច និងគណនេយ្យភាពរបស់រដ្ឋសម្រាប់ការបែងចែកធនធានប្រកបដោយយុត្តិធម៌  និងការផ្តល់សេវាសាធារណៈឆ្លើយតបយេនឌ័រប្រកបដោយគុណភាព។

## ផលជះជាយុទ្ធសាស្ត្រ

- ការកើនឡើងនូវការបែងចែកថវិកាសម្រាប់សេវាសាធារណៈឆ្លើយតបយេនឌ័រ រួមមានការអប់រំ និងសុខាភិបាលនៅតំបន់គោលដៅ
- ការកើនឡើងនៃការចូលរួមរបស់សាធារណៈ និងគណនេយ្យភាពរបស់រដ្ឋក្នុងអភិបាលកិច្ចសេដ្ឋកិច្ច និងការបែងចែកធនធានប្រកបដោយយុត្តិធម៌
- ការពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងយុវជនដើម្បីតស៊ូមតិ និងសន្ទនាលើបញ្ហាទាក់ទងនឹងសេវាអប់រំ និងសុខាភិបាលឆ្លើយតបយេនឌ័រ





# ការឆ្លើយតបជំនួយមនុស្សធម៌

ស្ត្រី និងយុវជនជាក្រុមគោលដៅស្នូលនៃភាពជាអ្នកដឹកនាំក្នុងការឆ្លើយតបផ្នែកមនុស្សធម៌របស់យើង និងកសាងសហគមន៍ដែលមានភាពធន់។

ជាផ្នែកមួយនៃការកម្មវិធីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ  អង្គការអាក់សិនអេតកម្ពុជាផ្តោតលើ**ការពង្រឹងអំណាច និងជំរុញការត្រៀមបង្ការ និងឆ្លើយតបលើការងារសង្គ្រោះបន្ទាន់ដែលដឹកនាំដោយស្ត្រី តាមរយៈការពង្រឹងភ្នាក់ងារដែលដឹកនាំដោយស្ត្រី និងយុវជន** ជាពិសេសនៅតំបន់ដាច់ស្រយាល ដើម្បីលើកកម្ពស់ការចូលរួមដោយពេញលេញ និងភាពជាអ្នកដឹកនាំរបស់ពួកគេក្នុងអភិបាលកិច្ចមូលដ្ឋាន និងថ្នាក់ក្រោមជាតិ និងក្នុងការបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ។

យើងគាំទ្រយុវជន ជាពិសេសស្ត្រីវ័យក្មេង ឱ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សមត្ថភាព ដែលនឹងផ្តល់អំណាចដល់ពួកគេក្នុងការបង្កើតការស្រាវជ្រាវផ្អែកលើភស្តុតាង ដើម្បីជះឥទ្ធិពលដល់ការធ្វើការសម្រេចចិត្តលើយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយនៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ។






# ABOUT US

*A Catalyst for Change*

**ActionAid Cambodia (AAC)** is both a catalyst and a contributor to social change processes. AAC envisages that Cambodians, especially women and young people, will be participating equitably at all levels to influence and achieve social, economic and climate justice that improves their quality of life through the just redistribution of resources, sustainable livelihoods, and access to free quality public services.

We work with the poorest and most excluded men, women and children in Cambodia, making long-term commitments to advance their human rights and transform the world in which their children grow up.

## OUR PROGRAMME PRIORITY

**01**



Climate Change and Resilience Building

**02**



Quality Education, Technology and Resilient Life Skills

**03**



Resourcing For Gender-Responsive Public Services

# HUMAN RIGHTS BASED APPROACH

AAC adopts a human rights-based approach, underpinned with intersectional feminist analysis and the Ten Feminist Leadership Principles into all aspects of its programme delivery and organisational development to ensure equal participation in decision-making processes at all levels.



# OUR PARTNERSHIP

At AAC, we work hand in hand with civil society organizations, social and labor groups, and community networks to create meaningful change. Our mission is to **engage closely with people living in poverty**, including **smallholder farmers, community fisheries and protected areas, children and young people**, supporting their efforts to build resilience against disasters and climate change while safeguarding their rights to livelihood and resources. We champion civic participation and advocate for accountability of relevant authorities or the state in the fair redistribution of resources and the delivery of quality, gender-responsive public services—especially in education and health. Our commitment extends to tackling the root causes of violence against women and girls and advancing women's economic justice.




# WHERE WE WORK

AAC presents in six provinces and cities; they include **Kampot, Koh Kong, Pursat, Kampong Thom, Oddar Meanchey, and Phnom Penh Municipality**.

AAC also plans to expand into more provinces of **coastal areas and the Tonle Sap region** to strengthen forestry and fishery networks and protect natural resources and local livelihoods.

# CLIMATE CHANGE AND RESILIENCE BUILDING



## Desired Change

Women and young people lead increased resilience to climate change and access to resources for sustainable livelihood in their families and communities.

## Strategic Outcomes

- Climate change adaptation and disaster risk reduction
- Sustainable 'resilient livelihood models' and access to resources
- Influencing policies and accountability of state and private actors in natural resource management, agroecology practices and climate justice.





# QUALITY EDUCATION, TECHNOLOGY AND RESILIENT LIFE SKILLS

## Desired Change

Children have improved access to quality education and technology training which incorporates resilient local life skills.

## Strategic Outcomes

- Improved quality of teaching through creative teaching methodologies
- Enhanced education for all children and young people which responds to their grade level and ICT skills requirements; and improved social skills through resilient life skills education
- Improved monitoring of quality education in schools through strengthened community participation and ownership as well as empowered School Management Committees (SMCs)
- Increased influence on education policy and practice at the national level





# RESOURCING FOR GENDER-RESPONSIVE PUBLIC SERVICES

## Desired Change

Increased public participation in influencing economic governance and state accountability for the just redistribution of resources and delivery of quality, gender-responsive public services.

## Strategic Outcomes

- Increased national and sub-national budget allocation for gender-responsive public services including education and health in target areas
- Increased public participation and state accountability as regards economic governance practices and the just redistribution of resources
- Strengthened leadership of women and young people to advocate and engage on gender-responsive education and health services





# HUMANITARIAN RESPONSE

*We place women and young people at the center of our humanitarian response, and build resilient communities.*

As part of climate change adaptation and disaster risk reduction of the climate change and resilience building programme, AAC works to **empower and drive a transformative women-led emergency preparedness, responses and prevention through strengthening agencies of women and young people**, especially in remote areas to promote their meaningfully participation and leadership in local and sub-national governance and disaster prevention and responses.

We engage and support young people, especially young women, to engage in capacity development activities that will empower them to develop action-oriented and evidence-based research to influence decision-making on climate change mitigation and disaster risk reduction strategies in their local communities.



actionaid

# យើងបន្ទរសំឡេងរបស់ដៃគូ បុគ្គលិក និងសហគមន៍របស់យើង

*We amplify the voices of ActionAid Cambodia’s* ***partners, staff, and communities.***




## ប្រព័ន្ធទំនាក់ទំនងរបស់យើង-Our Contact

e-mail.cambodia@actionaid.org
actionaid_cambodia_
ActionAidCambodia
(+855) 23 211 462
ActionAid Cambodia
actionaid_cambodia_